ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់
លេខ ២៦/២១ លស/ម.ត.ឯ.ច.

ថ្ងៃពុធ ៧កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១

**សូមគោរពជូន**
**លោកចៅក្រម យូ ឧត្តារ៉ា និងលោកស្រីចៅក្រម Claudia FENZ**

**កម្មវត្ថុ៖** សំណើនៃការចូលរួមចំណែកជាគំនិត នៅក្នុងមុខងារដែលនៅសេសសល់របស់អ.វ.ត.ក. ។

សេចក្តីដូចមានក្នុងកម្មវត្ថុខាងលើ នាងខ្ញុំសូមគោរពជម្រាបជូន**លោកចៅក្រម យូ ឧត្តារ៉ា និងលោកស្រីចៅក្រម Claudia FENZ** មេត្តាជ្រាបថា ដើម្បីឆ្លើយតបទៅនឹងសំណើនៃការចូលរួមចំណែកជាគំនិត នៅក្នុងមុខងារដែលនៅសេសសល់របស់អ.វ.ត.ក. មជ្ឈមណ្ឌលសូមចូលរួមជាគំនិតខ្លះៗ ដើម្បីអនុវត្តនូវសកម្មភាពដែលពាក់ព័ន្ធនឹងកេរដំណែល និងសំណល់នៃអ.វ.ត.ក. រួមបញ្ចូលទាំងគម្រោងសំណង របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ ដូចខាងក្រោម៖

**១. លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹង មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអ.វ.ត.ក.**

ការបង្កើតមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់(ម.ត.ឯ.ច.) ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងការទទួលស្គាល់មជ្ឈមណ្ឌលចំពោះមុខច្បាប់ ៖

១. ការផ្លាស់ប្តូរលិខិតរវាងរដ្ឋាភិបាលកម្ពុជា ជាមួយអង្គការសហប្រជាជាតិនៅថ្ងៃទី២២ និង២៨ ខែឧសភា ឆ្នាំ២០១៥ ជាកិច្ចព្រមព្រៀង នៅក្នុងការផ្តល់សំណុំរឿង០០១ ទាំងឯកសាររឹង និងឯកសារទន់ នៅចំពោះមុខអ.វ.ត.ក.

២. អនុក្រឹត្យលេខ ១៥៩ អនក្រ/ប.ក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពី ការរៀបចំនិងប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអ.វ.ត.ក.

៣. អនុស្សរណៈយោគយល់រវាងមជ្ឈមណ្ឌល និងអ.វ.ត.ក. ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦

៤. ការសម្រេច និងឯកភាពជាគោលការណ៍ ដោយរាជរដ្ឋាភិបាល ក្នុងការដាក់បញ្ចូលមជ្ឈមណ្ឌល ជាសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០២ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦

៥. ការទទួលស្គាល់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ជាសំណាងដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ដោយអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨

៦. ការផ្លាស់ប្តូរលិខិតរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ លើកិច្ចព្រមព្រៀងបំពេញបន្ថែម ក្នុងសំណុំរឿង០០២/០២ ថ្ងៃទី៣១ ខែសីហា និងថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨

**២. ការចូលរួមជាគំនិតពាក់ព័ន្ធនឹងកិច្ចការដែលនៅសេសសល់៖**

ក្រោយពីបានទទួលលិខិតជូនដំណឹងស្តីពីការចូលរួមយោបល់រួចមក មជ្ឈមណ្ឌលក៏បានពិនិត្យលើតួនាទីភារកិច្ចរបស់ខ្លួនស្របតាមអនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអ.វ.ត.ក. និងឯកសារពាក់ព័ន្ធមួយចំនួនទៀត។ ដូច្នេះ មជ្ឈមណ្ឌលសូមស្នើសុំចូលរួមសហប្រតិបត្តិការជាមួយអ.វ.ត.ក. ពាក់ព័ន្ធនឹងកិច្ចការដែលនៅសេសសល់ដូចខាងក្រោម៖

១. ប្រមូលឯកសារនានា រួមទាំងឯកសាររដ្ឋបាល សៀវភៅក្នុងបណ្ណាល័យ រូបថត រូបភាព ខ្សែអាត់សំឡេង វីដេអូ បណ្ណប្រកាស សម្ភារៈអប់រំ...។ល។ នៅតាមផ្នែកនីមួយៗនៃអង្គភាពចំណុះរបស់អ.វ.ត.ក. ទាំងឯកសាររឹង និងឯកសារទន់ សម្រាប់ជាឯកសារពាក់ព័ន្ធបន្ថែម ក្រៅពីសំណុំរឿងរបស់អ.វ.ត.ក. ដើម្បីតម្កល់នៅមជ្ឈមណ្ឌលឯកសារច្បាប់

២. បង្កើតវិចិត្រសាល និងពិព័រណ៍អចិន្ត្រៃយ៍ស្តីអំពីប្រវត្តិនៃដំណើរការរបស់អ.វ.ត.ក. នៅមជ្ឈមណ្ឌលឯកសារច្បាប់

៣. ទំនាក់ទំនងការចុះផ្សព្វផ្សាយប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងទស្សនកិច្ច

៤. បង្កើតកម្មវិធីទូរស័ព្ទដៃ និងបញ្ចូលទិន្នន័យឯកសារស្រាវជ្រាវប្រភេទសំណុំរឿងសាធារណៈទាំងអស់នៅក្នុងកម្មវិធីទូរសព្ទដៃ ដើម្បីបម្រើដល់ការស្រាវជ្រាវឲ្យបានទូលំទូលាយ

៥. បង្កើតវីដេអូ ឬចងក្រងជាឯកសារនីតិវិធីសវនការ របស់ អ.វ.ត.ក. ទុកសម្រាប់និស្សិតស្រាវជ្រាវ

៦. បង្កើតសវនាការប្រឌិត នៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ សម្រាប់និស្សិត ឬអ្នកបម្រើការងារក្នុងវិស័យច្បាប់

៧. បង្កើតកិច្ចសហប្រតិបត្តិការរវាងម.ត.ឯ.ច. និង អ.វ.ត.ក. ក្នុងការគ្រប់គ្រង រៀបចំ និងបែងចែកប្រភេទចំណាត់ថ្នាក់ឯកសាររបស់អ.វ.ត.ក.

៨. បង្កើតកម្មវិធីផ្សព្វផ្សាយ និងសិក្ខានានាពាក់ព័ន្ធនឹងសមិទ្ធផល និងកិច្ចដំណើរការការងារដែលនៅសេសសល់របស់អ.វ.ត.ក. នៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ដើម្បីឲ្យសាធារណជនជាតិ និងអន្តរជាតិបានស្គាល់ ម.ត.ឯ.ច. ជាផ្នែកមួយនៃសំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០២

៩. គាំទ្រមជ្ឈមណ្ឌលក្នុងការរៀបចំបង្កើតសិក្ខាសាលា និង/ឬ វគ្គបណ្តុះបណ្តាលខ្លីៗពាក់ព័ន្ធនឹងរបបខ្មែរក្រហម និងអ.វ.ត.ក.

១០. បង្កើតកម្មវិធីសម្ភាសន៍ជនរងគ្រោះ ឬអ្នករស់រានមានជីវិតក្នុងរបបខ្មែរក្រហម ដើម្បីចែករំលែកបទពិសោធឲ្យក្មេងជំនាន់ក្រោយបានដឹងពីរបបនោះ

**៣. សំណូមពរ**

- សូមបញ្ចូលព័ត៌មានអំពីមជ្ឈមណ្ឌលឯកសារច្បាប់ ព្រមទាំងគេហទំព័រទៅក្នុង បញ្ជីឯកសារយោងនៃព័ត៌មានមុខងារដែលនៅសេសសល់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតរបស់អ.វ.ត.ក. នាពេលអនាគត។

អាស្រ័យហេតុនេះ សូមលោកចៅក្រម យូ ឧត្តារ៉ា និងលោកស្រីចៅក្រម Claudia FENZ មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូមលោកចៅក្រម យូ ឧត្តារ៉ា និង លោកស្រីចៅក្រម Claudia FENZ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

**មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់**
**ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ប្រធាន**

Savon

**ជា សាវ៉ុន**